**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)
លេខ៖..០៩៥/២១..គ.វ.ក-១៩

ថ្ងៃ.ច័ន្ទ.....៨កើត..... ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី..១៩...... ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២
## ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីចូលរួមអនុវត្តតាមវិធានការបិទខ្ទប់ភូមិសាស្ត្រក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាលរបស់រាជរដ្ឋាភិបាល សំដៅទប់ស្កាត់មហន្តរាយនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងជានាបាននូវការបន្តការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ជូនដល់បុគ្គលដែលត្រូវដល់វេនចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ គ.វ.ក-១៩ សូមជូនដំណឹង និងណែនាំ ដូចខាងក្រោម៖

**ក. អំពីការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ និងស៊ីណូហ្វាម៖**

**១. ដំណើរការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ (ស៊ីណូវ៉ាក់ និងស៊ីណូហ្វាម) នៅរាជធានីភ្នំពេញ ៖**

**១.១. កាលបរិច្ឆេទនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅរាជធានីភ្នំពេញ ៖**

ដំណើរការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ (ស៊ីណូវ៉ាក់ និងស៊ីណូហ្វាម) នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ តាមតារាងបែងចែកក្នុងឧបសម្ព័ន្ធទី១។

**១.២. ទីតាំងដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ៖**

- ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីរាជការចំណុះក្រសួងមហាផ្ទៃ និងបុគ្គលដទៃទៀត ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ នៅតាមមន្ទីរពេទ្យជាតិ ក្រសួងស្ថាប័ននានា ក្រុមហ៊ុន និងទីតាំងមួយចំនួនទៀតកន្លងទៅនេះ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅតាមទីតាំងដែលមានក្នុងខណ្ឌដែលខ្លួនកំពុងរស់នៅ **ដោយមិនឱ្យឆ្លងខណ្ឌនោះទេ** ដែលទីតាំងទាំងនោះ មានបង្ហាញជូនដូចមានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២។
- ចំពោះបុគ្គល ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១រួចហើយនៅតាមខណ្ឌទាំង១៤ ដែលរៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ នឹងត្រូវចាប់ផ្តើមចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ទៅតាមថ្ងៃ-ខែ-ឆ្នាំដូចដែលបានជម្រាបជូនសាមីខ្លួនផ្ទាល់នៅថ្ងៃដែលចាក់ដូសលើកទី១នោះ ទៅតាមទីតាំងដូចមានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ នៅតាមខណ្ឌដែលខ្លួនកំពុងរស់នៅ **ដោយមិនឱ្យឆ្លងខណ្ឌជាដាច់ខាត**។

- ចំពោះកម្មករ-កម្មការិនី ដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ដែលបានរៀបចំចាក់ដោយពេទ្យការងារ ត្រូវទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅតាមទីតាំងដែលនឹងកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **ដោយមិនឱ្យឆ្លងខណ្ឌជាដាច់ខាត ។**
- ចំពោះកងទ័ព គ្រួសារកងទ័ព និងបុគ្គល ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ដែលរៀបចំដោយអង្គភាពចំណុះឱ្យក្រសួងការពារជាតិ ហើយត្រូវដល់ពេលចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ សូមអញ្ជើញទៅចាក់នៅតាមទីតាំងដែលនឹងចាត់ចែងទទួលខុសត្រូវដោយក្រសួងការពារជាតិ **ដោយសំណូមពរមិនឱ្យឆ្លងខណ្ឌឡើយ។** ប្រសិនបើបុគ្គលដែលពាក់ព័ន្ធលើការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ត្រង់ចំណុចនេះ មានបញ្ហា ឬចម្ងល់ សូមទាក់ទងទៅលេខទូរស័ព្ទ ០៩៧ ៧២៣ ២២១១ ឬ ០៩៧ ៧៩៩ ៩៩៧៧ ដើម្បីទទួលបានព័ត៌មានបន្ថែម។

**២. ដំណើរការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ (ស៊ីណូវ៉ាក់ និងស៊ីណូហ្វាម) នៅក្រុងតាខ្មៅ នៃខេត្តកណ្តាល ៖**

**២.១. កាលបរិច្ឆេទនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២នៅក្រុងតាខ្មៅ នៃខេត្តកណ្តាល៖**

ដំណើរការនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ (ស៊ីណូវ៉ាក់ និងស៊ីណូហ្វាម) នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១ ទៅតាមកាលបរិច្ឆេទបែងចែកនៅក្នុង**ឧបសម្ព័ន្ធទី១**។

**២.២. ទីតាំងដែលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ៖**

បុគ្គលដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ហើយកំពុងស្នាក់នៅក្នុងក្រុងតាខ្មៅនៃខេត្តកណ្តាល ត្រូវអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅ **មន្ទីរពេទ្យបង្អែកជ័យជំនះ ឬមណ្ឌលសុខភាពស្វាយរលំ** នៃភូមិសាស្ត្រក្រុងតាខ្មៅ **ដោយមិនឱ្យឆ្លងមករាជធានីភ្នំពេញ ឬស្រុកផ្សេង ជាដាច់ខាត ។**

**៣. ចំពោះបុគ្គលដែលកំពុងស្ថិតនៅក្នុងវិធានការបិទខ្ទប់ មិនអនុញ្ញាតឱ្យធ្វើដំណើរឆ្លងរាជធានីខេត្ត ៖**

ចំពោះបុគ្គលដែលដល់ពេលត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ហើយកំពុងអនុវត្តវិធានការបិទខ្ទប់នៅតាមរាជធានី-ខេត្ត សូមទំនាក់ទំនងជាមួយអនុគណកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត ឬអាជ្ញាធរមូលដ្ឋាន ឬមន្ទីរ សុខាភិបាលរាជធានី-ខេត្ត ដែលបុគ្គលនោះកំពុងស្នាក់នៅ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសលើកទី២ ដោយមិនត្រូវឱ្យហួសថ្ងៃកំណត់ចាក់ដូសទី២នោះឡើយ (មិនឱ្យហួសពី២៨ថ្ងៃបន្ទាប់ពីចាក់ដូសទី១រួចហើយ) និងត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ លើកទី១ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬឆាយា (ក្នុងករណីបុគ្គលដែលមិនបានយកមកជាមួយនូវប័ណ្ណចាក់វ៉ាក់សាំងលើកទី១ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត បុគ្គលនោះអាចបង្ហាញឯកសារទាំងនេះតាមប្រព័ន្ធអេឡិកត្រូនិកបាន)។

អនុគណកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត អាជ្ញាធរមូលដ្ឋាន ឬមន្ទីរសុខាភិបាលរាជធានី-ខេត្ត នៃទីតាំងរបស់បុគ្គលដែលត្រូវទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ត្រូវជួយសម្រួលដល់បុគ្គលនោះ ឱ្យបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងករណីបុគ្គលដែលត្រូវទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ មិនបានយកមកជាមួយនូវប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ហើយបានបង្ហាញប័ណ្ណនោះ តាមប្រព័ន្ធអេឡិកត្រូនិក អាជ្ញាធរមានសមត្ថកិច្ចនៃទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ នោះ ត្រូវចេញលិខិតបញ្ជាក់ថាបុគ្គលនោះ បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ដោយក្នុងលិខិតបញ្ជាក់ត្រូវសរសេរ ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ភេទ អាសយដ្ឋានរបស់បុគ្គលនោះ និងកាលបរិច្ឆេទ ទីតាំង នៃការចាក់វ៉ាក់សាំងដូសទី២ និងឈ្មោះវ៉ាក់សាំងដែលបានចាក់ដូសទី២នៅទីតាំងរបស់ខ្លួនរួចហើយនោះ ព្រមទាំងមានដាក់ឈ្មោះអ្នកទទួលខុសត្រូវដែលចេញលិខិតបញ្ជាក់នោះ និងមានចុះហត្ថលេខា (សូមមើលគំរូលិខិតបញ្ជាក់ភ្ជាប់មកជាមួយ ដូចក្នុងឧបសម្ព័ន្ធទី៣)។

**ខ. អំពីការចាក់វ៉ាក់សាំងកូវីសែល**(Covishield)**ដូសទី២៖**

ដូចបានបញ្ជាក់ក្នុងសេចក្តីណែនាំរបស់ គ.វ.ក-១៩ លេខ ០៨៧/២១ គ.វ.ក-១៩ ចុះថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០២១ រួចមកហើយ ចំពោះការចាក់វ៉ាក់សាំងកូវីសែល (ដែលទទួលបានអាជ្ញាប័ណ្ណផលិតដោយអាស្ត្រាហ្សេនីកា) ពេលវេលាដែលត្រូវចាក់លើកទី២នោះ ត្រូវនៅចន្លោះសប្តាហ៍ទី៨ និងទី១២ ដោយគិតចាប់ពីថ្ងៃដែលបានចាក់វ៉ាក់សាំងកូវីសែលដូសលើកទី១ ដែលវ៉ាក់



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

សាំងប្រភេទនេះ មានចាក់នៅតែរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ តែប៉ុណ្ណោះ។ បើគិតចាប់ពីថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០២១ ដែលជាថ្ងៃបានចាប់ផ្ដើមចាក់ដូសលើកទី១នោះ រហូតមកដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ នេះ គឺនៅមិនទាន់ដល់ពេល ដែលត្រូវចាក់ដូសទី២ នោះទេ។ ហេតុនេះ គ.វ.ក-១៩ នឹងធ្វើការជូនដំណឹងស្ដីពីការចាក់វ៉ាក់សាំងកូវីសែលដូសទី២ នៅពេលក្រោយ។

**គ. អំពីកិច្ចសហការ សម្របសម្រួល សម្រាប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ៖**

**១. ចំពោះក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរមូលដ្ឋាន ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី២**

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌក្រសួង ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ រដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្ដាល ព្រមទាំងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងខេត្តកណ្ដាល ត្រូវសហការរៀបចំទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ព្រមទាំងចាត់ចែងគ្រប់គ្រងសណ្ដាប់ធ្នាប់ និងការអនុវត្តវិធានការសុខាភិបាល ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ នៅតាមទីតាំងចាក់វ៉ាក់សាំងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្សព្វផ្សាយជូនបុគ្គលិក-មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន នូវទីតាំង និងពេលវេលានៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ដូចមានក្នុងឧបសម្ព័ន្ធទី១ និងទី២ ដោយ **មិនឱ្យឆ្លងខណ្ឌ ឬខេត្ត ជាដាច់ខាត**។

**២. ចំពោះក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន ដែលមិនមាននៅក្នុងឧបសម្ព័ន្ធទី២**

ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត និងអាជ្ញាធរមូលដ្ឋាន ដែលមិនមាននៅក្នុងឧបសម្ព័ន្ធទី២ ត្រូវសហការ និងផ្សព្វផ្សាយជូនដល់បុគ្គលិក និងមន្ត្រីរាជការនៅក្រោមឱវាទរបស់ខ្លួន និងប្រជាជនដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលមាននៅក្នុងឧបសម្ព័ន្ធទី២ ដោយ **មិនឱ្យឆ្លងខណ្ឌ ឬខេត្ត ជាដាច់ខាត**។ រីឯពេលវេលាដែលត្រូវទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ សូមពិនិត្យមើលតាមកាលកំណត់របស់ឧបសម្ព័ន្ធទី១។

**៣. ចំពោះអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្តផ្សេងទៀត**

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវចាត់ចែងរៀបចំការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ គ្រប់គ្រងសណ្ដាប់ធ្នាប់ និងការអនុវត្តវិធានការសុខាភិបាល ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ នៅតាមទីតាំងចាក់វ៉ាក់សាំងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្សព្វផ្សាយជូនបុគ្គលិក-មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅតាមរាជធានី-ខេត្តរបស់ខ្លួន ព្រមទាំងផ្សព្វផ្សាយនូវទីតាំង និងពេលវេលានៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ (ដូចមានក្នុងឧបសម្ព័ន្ធទី១ និងទី២ សម្រាប់រាជធានីភ្នំពេញ) នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយ **មិនឱ្យឆ្លងរាជធានី-ខេត្ត ជាដាច់ខាត**។

**ឃ. អំពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ សម្រាប់**

យោងលើសេចក្ដីសម្រេចលេខ ៥០ ស.សរ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ នៅក្នុងភូមិសាស្ត្រដែលត្រូវបិទខ្ទប់ ត្រូវបានផ្អាកជាបណ្ដោះអាសន្នក្នុងរយៈពេលបម្រាមបិទខ្ទប់នេះ។ ការបើកដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ឡើងវិញ ត្រូវរង់ចាំការសម្រេចជាថ្មីរបស់រាជរដ្ឋាភិបាល។

គ.វ.ក-១៩ សូមអំពាវនាវដល់សាធារណជនទាំងអស់ ត្រូវចូលរួមចំណែកអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ដែលបង្ហាញពីការទទួលខុសត្រូវរបស់បងប្អូនក្នុងការរួមចំណែកទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីឆាប់បានវិលត្រឡប់ទៅដំណើរការជាប្រក្រតីនូវការរស់នៅរបស់បងប្អូន រួមទាំងសកម្មភាពសេដ្ឋកិច្ច និងសង្គមផ្សេងៗឡើងវិញ ក្នុងពេលខាងមុខនេះ។

ជាមួយគ្នានេះដែរ ទោះបីជាបុគ្គលម្នាក់ៗបានទទួលវ៉ាក់សាំងកូវីដ-១៩ រួចហើយក្ដី ក៏ត្រូវតែបន្តអនុវត្តវិធានសុខាភិបាល **៣ការពារ** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង **៣កុំ** (កុំទៅកន្លែងមានមនុស្សកុះករច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ ក៏ដូចជានៅក្នុងប្រទេសកម្ពុជា។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ សូមទំនាក់ទំនងតាមលេខទូរស័ព្ទខាងក្រោមនេះ៖

ក- ក្រុមការងារទំនាក់ទំនងសាធារណៈ/លេខាធិការដ្ឋាន

| | | |
|---|---|---|
| ០១២ ៧៧៧ ៧៦០ | ០១២ ៩១៦ ០៩៩ | ០១២ ៩០៤ ៣៨៥ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៨៥ ៧៧៧ ០៥៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធាន**
**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

វេជ្ជ. ឱ្យ វណ្ណឌីន



ទីស្ដីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ឧបសម្ព័ន្ធទី១

## កាលបរិច្ឆេទចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ( ស៊ីណូវ៉ាក់ និងស៊ីណូហ្វាម ) នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដោយមិនឱ្យឆ្លងក្រុង-ខណ្ឌ

| ល.រ. | ថ្ងៃ ខែ ឆ្នាំ អ្នកដែលបានចាក់ដូសទី១ | ថ្ងៃ ខែ ឆ្នាំ អ្នកនឹងត្រូវមកចាក់ដូសទី២ |
|---|---|---|
| ១ | ០១/មេសា/២០២១ | ២០/មេសា/២០២១ |
| ២ | ០២/មេសា/២០២១ | ២១/មេសា/២០២១ |
| ៣ | ០៣/មេសា/២០២១ | ២២/មេសា/២០២១ |
| ៤ | ០៤/មេសា/២០២១ | ២៣/មេសា/២០២១ |
| ៥ | ០៥/មេសា/២០២១ | ២៤/មេសា/២០២១ |
| ៦ | ០៦/មេសា/២០២១ | ២៥/មេសា/២០២១ |
| ៧ | ០៧/មេសា/២០២១ | ២៦/មេសា/២០២១ |
| ៨ | ០៨/មេសា/២០២១ | ២៧/មេសា/២០២១ |
| ៩ | ០៩/មេសា/២០២១ | ២៨/មេសា/២០២១ |
| ១០ | ១០/មេសា/២០២១ | ២៩/មេសា/២០២១ |
| ១១ | ១១/មេសា/២០២១ | ៣០/មេសា/២០២១ |
| ១២ | ១២/មេសា/២០២១ | ០១/ឧសភា/២០២១ |
| ១៣ | ១៣/មេសា/២០២១ | ០២/មេសា/២០២១ |
| ១៤ | ១៤/មេសា/២០២១ | ០៣/ឧសភា/២០២១ |

ឧបសម្ព័ន្ធទី២

## ទីតាំងចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ និងស៊ីណូហ្វាមសម្រាប់ដូសទី២ នៅរាជធានីភ្នំពេញ ដោយមិនឱ្យឆ្លងខណ្ឌ-ខណ្ឌ ដាច់ខាត

| ល.រ. | ខណ្ឌ | ទីតាំងចាក់វ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) ដែលរៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ | ទីតាំងចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (Sinovac) |
|---|---|---|---|
| ១ | ច្បារអំពៅ | – មន្ទីរពេទ្យបង្អែកច្បារអំពៅ<br>– មណ្ឌលសុខភាពព្រែកឯង<br>– សាលាបឋមសិក្សាបឹងឈូកប្រជុំវង្ស<br>– មន្ទីរពេទ្យ១៦ឧសភា | – សាលាវិទ្យាល័យច្បារអំពៅ (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា)<br>– បុរីប៉េងហួតបឹងស្នោរ (រៀបចំដោយក្រុមហ៊ុនប៉េងហួតគ្រុប) |
| ២ | ចំការមន | – វិទ្យាល័យទួលទំពូង<br>– មណ្ឌលសុខភាពផ្សារដើមថ្កូវ | – សាលា ISC (កោះពេជ្រ) (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– វិទ្យាល័យផ្សារដើមថ្កូវ (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា)<br>– សណ្ឋាគារកាំបូឌីយ៉ាណា (រៀបចំដោយ ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប) |
| ៣ | បឹងកេងកង | – វិទ្យាល័យបឹងកេងកង | – ក្រសួងផែនការ (រៀបចំដោយក្រសួងផែនការ)<br>– វិទ្យាល័យទួលស្វាយព្រៃ (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ៤ | ដូនពេញ | – មន្ទីរពេទ្យចតុមុខ<br>– វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំ | – ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)<br>– សាលាបឋមសិក្សាកុលាប១ (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា) |
| ៥ | ៧ មករា | – សាលាបឋមសិក្សាសំពៅមាស<br>– មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ | – ក្រសួងទេសចរណ៍ (រៀបចំដោយក្រសួងទេសចរណ៍)<br>– សាលាបឋមសិក្សាបាក់ទូក (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា) |
| ៦ | ឬស្សីកែវ | – មន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ<br>– សាលាបឋមសិក្សាឬស្សីកែវ<br>– មណ្ឌលសុខភាពគីឡូម៉ែត្រលេខ៩ | – ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ (រៀបចំដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់)<br>– វិទ្យាល័យឬស្សីកែវ(រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ៧ | ជ្រោយចង្វារ | – ផ្សារបុរីរុងរឿងជ្រោយចង្វារ<br>– មណ្ឌលសុខភាពជ្រោយចង្វារ | – វិទ្យាល័យជាស៊ីមជ្រោយចង្វារ (រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា) |
| ៨ | ព្រែកព្នៅ | – មណ្ឌលសុខភាពសំរោង<br>– មណ្ឌលសុខភាពពញាពន់ | – មន្ទីរពេទ្យបង្អែកព្រែកព្នៅ (រៀបចំដោយមន្ទីរពេទ្យបង្អែកព្រែកព្នៅ) |



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

| | | | |
|---|---|---|---|
| | | | – សាលាវិទ្យាល័យជាស៊ីមឈូកវ៉ា (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ៩ | ទួលគោក | – សាលាបឋមសិក្សាជាស៊ីមសន្ធម៉ុក<br>– មណ្ឌលសុខភាពទួលគោក<br>– សាលាបឋមសិក្សាទួលគោក | – សាលាបឋមសិក្សាទួលគោក (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– វិទ្យាល័យជាស៊ីមសន្ធរម៉ុក (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ១០ | ដង្កោ | – មន្ទីរពេទ្យបង្អែកដង្កោ<br>– មណ្ឌលសុខភាពព្រៃវែង<br>– មណ្ឌលសុខភាពពងទឹក<br>– មណ្ឌលសុខភាពជើងឯក | – វិទ្យាល័យទួលអំពិល (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– សាកលវិទ្យាល័យភូមិន្ទកសិកម្ម (រៀបចំដោយ សាកលវិទ្យាល័យភូមិន្ទកសិកម្ម) |
| ១១ | ពោធិ៍សែនជ័យ | – មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង<br>– សាលាបឋមសិក្សាជម្ពូវ័ន្ត<br>– មណ្ឌលសុខភាពសាមគ្គី | – សាលាបឋមសិក្សាតាំងកសាង (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា)<br>– អគ្គនាយកដ្ឋានប្រេងកាតនៅផ្លូវសហព័ន្ធ រុស្ស៊ី (រៀបចំដោយ ក្រសួងរ៉ែ និងថាមពល) |
| ១២ | សែនសុខ | – មណ្ឌលសុខភាពឃ្មួញ<br>– មណ្ឌលសុខភាពភ្នំពេញថ្មី<br>– មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ | – ក្រសួងពាណិជ្ជកម្ម (រៀបចំដោយក្រសួងពាណិជ្ជកម្ម)<br>– សាលាបឋមសិក្សាភ្នំពេញថ្មី (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ១៣ | មានជ័យ | – មណ្ឌលសុខភាពស្ទឹងមានជ័យ<br>– សាលាបឋមសិក្សាសន្សំកុសល | – បុរីដីបម៉ុង ផ្លូវ៦០ម (រៀបចំដោយក្រុមហ៊ុនដីបម៉ុងគ្រុប)<br>– សាលាបឋមសិក្សាចាក់អង្រែលើ (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |
| ១៤ | កំបូល | – មណ្ឌលសុខភាពបឹងធំ<br>– វិទ្យាល័យកំពូល | – សាលាបឋមសិក្សាកំបូល (រៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា) |

*សំគាល់៖ ចំពោះការចាក់វ៉ាក់សាំងស៊ីណូហ្វាម និងស៊ីណូវ៉ាក់ដូសទី២ អាចចាក់អំឡុងពេល១៤ ទៅ២៨ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី១។*



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩**
**ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

មន្ទីរសុខាភិបាលរាជធានី-ខេត្ត ..............................

ទីតាំងចាក់វ៉ាក់សាំង ..........................................

## លិខិតបញ្ជាក់ចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២
## (សម្រាប់បុគ្គលដែលមិនបានយកបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ លើកទី១ទៅតាមខ្លួន)

ក្រុមការងារចាក់វ៉ាក់សាំងកូវីដ-១៩ បញ្ជាក់ថា: ឈ្មោះ....................ភេទ......ថ្ងៃ-ខែ-ឆ្នាំកំណើត..........

អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ..........ផ្លូវលេខ............ឃុំ/សង្កាត់..................................

ស្រុក/ខណ្ឌ/ក្រុង.........................រាជធានី/ខេត្ត...........................។

ពិតជាបានមកចាក់វ៉ាក់សាំងកូវីដ-១៩ ឈ្មោះ............................ដូសទី២ នៅថ្ងៃទី..........................

នៅទីតាំង....................................................................................................

ស្ថិតនៅក្នុងឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ/ក្រុង.....................រាជធានី/ខេត្ត...........។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ដើម្បីប្រើប្រាស់យកទៅចុះឈ្មោះនៅទីតាំងដែលបានចាក់វ៉ាក់សាំងដូសទី២វិញ នៅពេលដែលវិធានការបិទខ្ទប់ត្រូវបានបញ្ចប់។

ថ្ងៃ.............................. ខែ......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី.............. ខែ............ ឆ្នាំ២០២១

**អ្នកទទួលខុសត្រូវ**